# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្តាល

**សំណុំរឿងព្រហ្មទណ្ឌលេខ ១១៨០ អក**
ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២០
**សំណុំរឿងស៊ើបសួរលេខ ៦៣៧ ស.ស**
ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២០
**សំណុំរឿងជំនុំជម្រះលេខ ១៤៨៥ ជរ**
ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២០
**សាលក្រមព្រហ្មទណ្ឌលេខ ១៧ ព.ឋ**
ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០២០

# សាលក្រម

## ក្នុងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តកណ្តាល

កាលបរិច្ឆេទនៃសវនាការ ៖ ថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២០ ។
សាលសវនាការ និងពេលវេលា ៖ សាល ៥ ម៉ោង ២ និង ៣០ នាទី រសៀល។
កាលបរិច្ឆេទនៃការប្រកាសសាលក្រម ៖ ថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០២០។
សាលសវនាការ និងពេលវេលា ៖ សាល ០៥ ម៉ោង ០២ រសៀល។
ក្រោមសមាសភាពជំនុំជម្រះ រួមមាន ៖

### ចៅក្រមជំនុំជម្រះ

លោក [redacted] ចៅក្រមសាលាដំបូងខេត្តកណ្តាល និងជាចៅក្រមជំនុំជម្រះ

### តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងខេត្តកណ្តាល

### ក្រឡាបញ្ជីសវនាការ

លោកស្រី [redacted] ក្រឡាបញ្ជីនៃសាលាដំបូងខេត្តកណ្តាល

### ដើម្បីជំនុំជម្រះ

លើសំណុំរឿងព្រហ្មទណ្ឌលេខ ១១៨០ អក ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២០ ដែលមាន៖

**ក. អំពីអត្តសញ្ញាណជនជាប់ចោទ**

១. ឈ្មោះ [redacted] ម៉ាហ្គោ ភេទប្រុស កើតឆ្នាំ ១៩៩៩ ជានីតិជន ជនជាតិខ្មែរ សញ្ជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តកណ្តាល ទីលំនៅភូមិ [redacted] ខេត្តកណ្តាល។

ឪពុកឈ្មោះ [redacted] តូ (រ) ម្តាយឈ្មោះ [redacted] ចន្ធី (រ) នៅលីវ។

ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ៖ ធ្លាប់ជាប់ពន្ធនាគារចំនួន ០២ ខែ។

កាលបរិច្ឆេទឃុំខ្លួនបណ្តោះអាសន្ន ៖ ថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២០។



Scanned with CamScanner

កាលបរិច្ឆេទនៃការរក្សាទុកឱ្យនៅជាប់ឃុំជាបណ្តោះអាសន្ន៖ ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២០។

២. ឈ្មោះ [redacted] **ភារក្ស** ភេទប្រុស កើតឆ្នាំ ២០០១ ជានីតិជន ជនជាតិខ្មែរ សញ្ជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិ[redacted] ខេត្តកណ្តាល ទីលំនៅភូមិ[redacted] ខេត្តកណ្តាល។

ឪពុកឈ្មោះ [redacted] ប៊ុណារិន (រ) ម្តាយឈ្មោះ [redacted] រ៉ា (រ) នៅលើវ ។

ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ៖ គ្មាន។

កាលបរិច្ឆេទឃុំខ្លួនបណ្តោះអាសន្ន៖ ថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២០។

កាលបរិច្ឆេទនៃការរក្សាទុកឱ្យនៅជាប់ឃុំជាបណ្តោះអាសន្ន៖ ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២០។

៣. ឈ្មោះ [redacted] **សៀងលី** ហៅ **ឈីត** ភេទប្រុស កើតឆ្នាំ ១៩៩៥ ជានីតិជន ជនជាតិខ្មែរ សញ្ជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិ[redacted] ខេត្តកណ្តាល ទីលំនៅភូមិ[redacted] ខេត្តកណ្តាល។

ឪពុកឈ្មោះ [redacted] សៀងឡេង (ស) ម្តាយឈ្មោះ [redacted] ស្រីតូច (ស) ប្រពន្ធឈ្មោះ [redacted] ចាន់សុខអាង មានកូនចំនួន ០១ នាក់។

ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ៖ គ្មាន។

កាលបរិច្ឆេទឃុំខ្លួនជាបណ្តោះអាសន្ន ៖ ថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២០។

កាលបរិច្ឆេទនៃការរក្សាទុកឱ្យនៅជាប់ឃុំជាបណ្តោះអាសន្ន៖ ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២០។

៤. ឈ្មោះ [redacted] **គីមហុង** ភេទប្រុស កើតឆ្នាំ ២០០០ ជានីតិជន ជនជាតិខ្មែរ សញ្ជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិ[redacted] ខេត្តតាកែវ ទីលំនៅភូមិ[redacted] ខេត្តកណ្តាល។

ឪពុកឈ្មោះ [redacted] សុខហៀង (រ) ម្តាយឈ្មោះ [redacted] ស្រីប៉ុច (រ) នៅលើវ។

ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ៖ គ្មាន។

កាលបរិច្ឆេទឃុំខ្លួនបណ្តោះអាសន្ន ៖ ថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២០។

កាលបរិច្ឆេទនៃការរក្សាទុកឱ្យនៅជាប់ឃុំជាបណ្តោះអាសន្ន៖ ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២០។

ត្រូវជាប់ចោទពីបទ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិបឹងខ្យាង ឃុំបឹងខ្យាង ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល កាលពីថ្ងៃទី០៦ ខែកក្កដា ឆ្នាំ ២០២០ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤០ និង មាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

**ដែលត្រូវបានបញ្ជូនមកជំនុំជម្រះតាមដីកាដំណោះស្រាយលេខ ១៣៣២ ដក.ដស ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ ២០២០ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកណ្តាល ដែលមានអង្គហេតុដូចខាងក្រោម៖**



Scanned with CamScanner

## អង្គហេតុដែលប្ដឹងមកតុលាការមានដូចតទៅ

មុនពេលកើតហេតុឈ្មោះ[redacted]ម៉ាហ្គោ ភេទប្រុស អាយុ ២១ ឆ្នាំ បានប្រើក្មួនចៅឱ្យទៅយកថ្នាំញៀនទិញពីឈ្មោះ ពៅ ភេទប្រុស នៅចំណុចស្ពានព្រែកព្នៅ រាជធានីភ្នំពេញ ដោយទាក់ទងតាមលេខទូរស័ព្ទ ដោយទិញចំនួន ២០០ (ពីររយ) ដុល្លារអាមេរិក។ លុះនៅថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២០ វេលាម៉ោង ១៤ និង ០០ នាទី ជនសង្ស័យឈ្មោះ[redacted]ម៉ាហ្គោ បានលក់ថ្នាំឱ្យទៅឈ្មោះ [redacted]សៀងលី ចំនួន ០១ កញ្ចប់។ រហូតដល់ថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២០ ឈ្មោះ [redacted] សៀងលី ក៏បានវែកថ្នាំញៀនលក់បន្តឱ្យឈ្មោះ[redacted]គីមហុង ចំនួន ០១ កញ្ចប់ ហើយឈ្មោះ[redacted]គីមហុង បានចេញពីផ្ទះឈ្មោះ[redacted]សៀងលី នៅភូមិបឹងខ្យាង ឃុំបឹងខ្យាង ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល ក៏ត្រូវសមត្ថកិច្ចចាប់ឃាត់ខ្លួន និងបន្តឃាត់ខ្លួនឈ្មោះ [redacted] សៀងលី, ឈ្មោះ[redacted]ភារក្ស និងឈ្មោះ [redacted]ម៉ាហ្គោ និងធ្វើការឆែកឆេររកឃើញថ្នាំញៀនចំនួន ០៦ កញ្ចប់ និងសម្ភារៈវេចខ្ចប់ និងសម្ភារៈប្រើប្រាស់មួយចំនួនទៀត បញ្ជូនទៅកាន់អធិការដ្ឋានគរបាលស្រុកកណ្ដាលស្ទឹង ដើម្បីចាត់ការតាមនីតិវិធី។

## អំពីកិច្ចពិភាក្សាដេញដោលលើអង្គសេចក្ដី

**ក. អំពីកិច្ចពិភាក្សាដេញដោលមុនពេលអង្គសេចក្ដី**

អំពីវិវាទកម្មស្ដីពីនិយតភាពនៃការកោះហៅ តាមមាត្រា ៣២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ៖ ពុំមានការលើកឡើង។

អំពីអញ្ញត្រកម្ម តាមមាត្រា ៣៤២ ដល់មាត្រា ៣៤៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ៖ ពុំមានការលើកឡើង។

**ខ. អំពីកិច្ចពិភាក្សាដេញដោលលើអង្គសេចក្ដី**

**១. ការសួរចម្លើយជនជាប់ចោទ**

**១.១** ជនជាប់ចោទឈ្មោះ[redacted]ម៉ាហ្គោ បានឆ្លើយនាពេលសវនាការថា៖ នៅថ្ងៃកើតហេតុខ្លួននៅផ្ទះជាមួយនឹងប្រពន្ធ ហើយក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនតែម្ដង នៅថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២០ ដោយសមត្ថកិច្ចឆែកឆេររកឃើញថ្នាំញៀននៅក្រោមគ្រែខ្លួនចំនួន ០៦ កញ្ចប់ ដោយថ្នាំញៀននោះខ្លួនទិញពីឈ្មោះ **ពៅ** ដោយខ្លួនទុកនៅក្នុងប្រអប់ឡាំងក្រដាសរៀងបួនជ្រុង។ ថ្នាំញៀននេះឈ្មោះ **ពៅ** ជាអ្នកផ្ញើមកខ្លួន ដើម្បីទុកប្រើប្រាស់។ ពីមុនមកខ្លួនមិនធ្លាប់ទិញថ្នាំញៀនពីឈ្មោះ **ពៅ** នោះទេ។ ចំពោះឈ្មោះ **សៀងលី** ខ្លួនស្គាល់នៅអំឡុងឆ្នាំ២០១៩ តាមរយៈមិត្តភក្ដិណែនាំ។ ឈ្មោះ **ពៅ** បច្ចុប្បន្នកំពុងឃុំខ្លួននៅក្នុងពន្ធនាគារ។ ថ្នាំញៀននេះ ឈ្មោះ **ពៅ** ឱ្យមិត្តភក្ដិរបស់វាដែលនៅខាងក្រៅយកមកឱ្យខ្លួន។ ពេលយកថ្នាំញៀនមកឈ្មោះ **ពៅ** បានប្រាប់មិត្តភក្ដិរបស់គេថា ឱ្យយកមកឱ្យខ្លួន។ ថ្នាំញៀននេះ ខ្លួនទិញពីឈ្មោះ **ពៅ** តម្លៃ **២០០.០០០ (ម្ភៃម៉ឺន) រៀល**។ ខ្លួនមិនធ្លាប់លក់ថ្នាំញៀននោះទេ ហើយក៏មិនធ្លាប់លក់ឱ្យឈ្មោះ **សៀងលី** ឈ្មោះ [redacted] **គីមហុង** និងឈ្មោះ[redacted]**ភារក្ស** ដែរ។ ខ្លួនចេះប្រើប្រាស់ថ្នាំញៀនដោយខ្លួនប្រើប្រាស់តែម្នាក់ឯងប៉ុណ្ណោះ។ ចំណែកឈ្មោះ [redacted] **ភារក្ស** ខ្លួនមិនធ្លាប់ប្រើប្រាស់ថ្នាំញៀនជាមួយនោះទេ។

**១.២.** ជនជាប់ចោទឈ្មោះ[redacted]**សៀងលី** បានឆ្លើយនាពេលសវនាការថា នៅថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២០ ខ្លួនត្រូវសមត្ថកិច្ចឃាត់ខ្លួន ដោយសមត្ថកិច្ចបានប្រាប់ខ្លួនថា ឃាត់បានប្អូនខ្លួនឈ្មោះ [redacted] **គីមហុង** ចំពោះថ្នាំ



Scanned with CamScanner

ញៀនដែលសមត្ថកិច្ចដកហូតបានចំនួន ០១ កញ្ចប់នោះ ខ្លួនទិញពីបុរសម្នាក់មិនស្គាល់ឈ្មោះច្បាស់តែលឺតែគេហៅឈ្មោះ **លុច្ឆ**។ ពីមុនមកនៅថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២០ ខ្លួនពិតជាបានទិញថ្នាំញៀនពីឈ្មោះ [redacted] **ម៉ាហ្គោ** ចំនួន ០១ កញ្ចប់តម្លៃ **៥០.០០០ (ប្រាំម៉ឺន) រៀល** ដោយទាក់ទងទិញតាមរយៈទូរស័ព្ទ ខ្លួនដឹងថា ឈ្មោះ **ហ្វ ម៉ាហ្គោ** លក់ថ្នាំញៀន ដោយសារអ្នកភូមិប្រាប់ថា ចង់បានថ្នាំញៀនឱ្យទាក់ទងទៅឈ្មោះ [redacted] **ម៉ាហ្គោ** ទៅ។ ខ្លួនទើបតែទិញពីឈ្មោះ [redacted] **ម៉ាហ្គោ** ចំនួន ០១ កញ្ចប់ ហើយក៏ទើបតែទិញលើកដំបូងដែរ ដោយនៅថ្ងៃទិញថ្នាំញៀននោះ ឈ្មោះ [redacted] **គីមហុង** (ប្អូនរបស់ខ្លួន) ជាអ្នកទៅយកថ្នាំញៀននោះ។ ពេលទិញថ្នាំញៀនថ្ងៃកើតហេតុនោះ ខ្លួនចូលលុយចំនួន **២០.០០០ (ពីរម៉ឺន)** រៀល ឈ្មោះ **គីមហុង** ចូលលុយចំនួន **៣០.០០០ (បីម៉ឺន)** រៀល ពេលទៅយកថ្នាំញៀននោះ មិនទាន់បានប្រើប្រាស់ផង ក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនឈ្មោះ ទិត គីមហុង តែម្តង។

**១.៣.** ជនជាប់ចោទឈ្មោះ [redacted] **ម៉ាហ្គោ** បានឆ្លើយថា ខ្លួនពិតជាបានលក់ថ្នាំញៀនឱ្យទៅឈ្មោះ [redacted] **សៀងលី** តែឈ្មោះ [redacted] **គីមហុង** ជាអ្នកមកយកថ្នាំញៀន ប្រាកដមែន។

**១.៤.** ជនជាប់ចោទឈ្មោះ [redacted] គីមហុង បានឆ្លើយថា ខ្លួនត្រូវសមត្ថកិច្ចឃាត់ខ្លួននៅថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២០ ខ្លួនស្គាល់ឈ្មោះ ផុន សៀងលី ដោយរាប់អានគ្នា។ នៅថ្ងៃកើតហេតុឈ្មោះ [redacted] **សៀងលី** បានឱ្យខ្លួនជិះម៉ូតូទៅយកថ្នាំញៀនតម្លៃ ៣០.០០០ **(បីម៉ឺន) រៀល** ទៅ ៤០.០០០ **(បួនម៉ឺន) រៀល** ពីបុរសម្នាក់មិនស្គាល់ឈ្មោះ។ ខ្លួនសូមបញ្ជាក់បន្ថែមថាឈ្មោះ [redacted] **សៀងលី** ក៏បានឱ្យខ្លួនទៅយកថ្នាំញៀនពីបុរសម្នាក់ឈ្មោះ **សាន** ប្អូនរបស់ឈ្មោះ [redacted] **ម៉ាហ្គោ**។ ថ្នាំញៀននោះ ខ្លួនមិនបានចូលលុយនោះទេ គ្រាន់តែឈ្មោះ [redacted] **សៀងលី** ឱ្យខ្លួនប្រហែលជា ១០ (ដប់) ដុល្លារអាមេរិក។ ពីមុនមកឈ្មោះ [redacted] **សៀងលី** ធ្លាប់បានប្រើប្រាស់ថ្នាំញៀនរួម។ នៅថ្ងៃកើតហេតុខ្លួនក៏ជិះត្រឡប់មកវិញ ក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួន ហើយដកហូតបានថ្នាំញៀនចំនួន ០១ កញ្ចប់ តែម្តង។ ចំពោះឈ្មោះ [redacted] ភារក្ស ខ្លួនក៏មិនធ្លាប់ស្គាល់ ប៉ុន្តែធ្លាប់ប្រើប្រាស់ថ្នាំញៀនរួមគ្នាពីមុនមក។ ខ្លួនទើបតែទៅយកថ្នាំញៀនពីឈ្មោះ [redacted] **ម៉ាហ្គោ** លើកទី០១ ប៉ុណ្ណោះ។ ថ្នាំញៀនដែលយកមកបំណងយកមកប្រើប្រាស់រួមគ្នាជាមួយនឹងឈ្មោះ [redacted] **សៀងលី** និងឈ្មោះ [redacted] **ភារក្ស**។ ចំពោះឈ្មោះ [redacted] **ភារក្ស** បានដឹងថាពួក ខ្លួនទៅទិញថ្នាំញៀន ដើម្បីប្រើប្រាស់រួមគ្នា ដោយឈ្មោះ [redacted] **ភារក្ស** ដឹងឬមិនដឹងខ្លួនក៏មិនច្បាស់ដែរ។

**១.៥.** ជនជាប់ចោទឈ្មោះ [redacted] **ភារក្ស** បានឆ្លើយនាពេលសវនាការថា ខ្លួនត្រូវសមត្ថកិច្ចឃាត់ខ្លួននៅ ថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២០ ដោយឃាត់នៅផ្ទះរបស់ឈ្មោះ [redacted] **សៀងលី** ខ្លួនស្គាល់ឈ្មោះ [redacted] **សៀងលី** រយៈពេលប្រហែល ០១ ខែប៉ុណ្ណោះ។ ខ្លួនធ្លាប់ប្រើប្រាស់ថ្នាំញៀនជាមួយនឹងឈ្មោះ **គីមហុង** នោះទេ។ ពីមុនមកខ្លួនធ្លាប់ប្រើប្រាស់ថ្នាំញៀនជាមួយនឹងមិត្តភក្តិ។ ចំណែកឈ្មោះ [redacted] **សៀងលី** ខ្លួនមិនធ្លាប់ប្រើប្រាស់ជាមួយទេ ប៉ុន្តែខ្លួនដឹងថា ពីរនាក់នោះប្រើប្រាស់ថ្នាំញៀន ដោយដឹងតាមរយៈមិត្តភក្តិប្រាប់ខ្លួនថាឈ្មោះ [redacted] **សៀងលី** និងឈ្មោះ [redacted] **គីមហុង** ក៏ចេះប្រើប្រាស់ថ្នាំញៀនដែរ។ ខ្លួនចេះប្រើប្រាស់ថ្នាំញៀនរយៈពេល ០៦ ខែមកហើយ ប៉ុន្តែមិនញឹកញាប់នោះទេ ។ ថ្នាំញៀនដែលប្រើប្រាស់រាល់ដង គឺមិត្តភក្តិជាអ្នកហៅខ្លួនឱ្យប្រើប្រាស់ជាមួយគេគឺ ខ្លួនមិនធ្លាប់ទិញដោយខ្លួនឯងនោះទេ។ នៅថ្ងៃកើតហេតុខ្លួនពិតជាបានទៅផ្ទះឈ្មោះ [redacted] **សៀងលី** ដើម្បីប្រើប្រាស់ថ្នាំញៀនរួមគ្នាប្រាកដមែន។

**សិទ្ធិនិយាយស្ដីរបស់ភាគី បន្ទាប់ពីចប់កិច្ចពិភាក្សាដេញដោល**

**ក. ការកត់សម្គាល់ខ្លីៗរបស់៖**

**១. ជនជាប់ចោទ៖**

១.១. ឈ្មោះ [redacted] ម៉ាហ្គោ បានសំណូមពរថា ខ្លួនស្នើសុំតុលាការបន្ធូរបន្ថយទោស ។

១.២. ឈ្មោះ [redacted] សៀងលី បានសំណូមពរថា ខ្លួនស្នើសុំតុលាការបន្ធូរបន្ថយទោស ។

១.៣. ឈ្មោះ [redacted] គីមហុង បានសំណូមពរថា ខ្លួនស្នើសុំតុលាការបន្ធូរបន្ថយទោស ។

១.៤. ឈ្មោះ [redacted] ភារក្ស បានសំណូមពរថា ខ្លួនស្នើសុំតុលាការបន្ធូរបន្ថយទោស ។

**ខ. សេចក្ដីសន្និដ្ឋាន៖**

**១. សេចក្ដីសន្និដ្ឋានប្ដឹងសុំរបស់តំណាងអយ្យការ៖**

ក្រោយពីបានស្ដាប់ការសួរដេញដោលនាពេលសវនាការ ឃើញថា ជនជាប់ចោទឈ្មោះ [redacted] **ម៉ាហ្គោ** ឈ្មោះ [redacted] **សៀងលី** ឈ្មោះ [redacted] **គីមហុង** ឈ្មោះ [redacted] **ភារក្ស** បានឆ្លើយសារភាពថា ថ្នាំញៀនដែលទិញនោះ គឺទិញពីឈ្មោះ [redacted] **ម៉ាហ្គោ** ហើយថ្នាំញៀនដែលទិញនោះ គឺយកមកប្រើប្រាស់រួមគ្នា ដែលអំពើនេះចាត់ទុកជាអំពើ **ចាត់ចែងឱ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ហេតុនេះស្នើសុំកែប្រែបទចោទប្រកាន់លើជនជាប់ចោទឈ្មោះ [redacted] **សៀងលី** ឈ្មោះ [redacted] **គីមហុង** ឈ្មោះ [redacted] **ភារក្ស** ពីបទ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិបឹងខ្យាង ឃុំបឹងខ្យាង ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល កាលពីថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្ដន្ទាទោសតាមមាត្រា ៤០ និង មាត្រា ៤៥ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន មកបទ **ចាត់ចែងឱ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** តាមបញ្ញត្តិមាត្រា ៤២ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

**២. មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ភារក្ស៖**

**លោក [redacted] ធ្វើសេចក្ដីសន្និដ្ឋានថា** ខ្លួនស្នើសុំទៅក្រុមជំនុំជម្រះឱ្យកូនក្ដីខ្លួនឈ្មោះ [redacted] ភារក្ស រួចផុតពីបទចោទប្រកាន់ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន។

**លោក [redacted] ធ្វើសេចក្ដីសន្និដ្ឋានថា** ខ្លួនស្នើសុំតុលាការសម្រេចឱ្យកូនក្ដីខ្លួនឈ្មោះ [redacted] ភារក្ស រួចផុតពីបទ ចាត់ចែងឱ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន។

*- ក្រោយពីបាន ស្ដាប់កិច្ចពិភាក្សាដេញដោលរួចហើយ*

*- ក្រោយពីបាន ស្ដាប់សិទ្ធិនិយាយស្ដីរបស់ភាគី បន្ទាប់ពីចប់កិច្ចពិភាក្សាដេញដោល*

## សំអាងហេតុ

**ក. អំពីសមត្ថកិច្ចនៃការជំនុំជម្រះរឿងក្ដី**

សាលាដំបូងខេត្តកណ្ដាលបានទទួលសំណុំរឿងព្រហ្មទណ្ឌលេខ **១១៤០ អ.ក** ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ ២០២០ ដែលមានជនជាប់ចោទឈ្មោះ [redacted] ម៉ាហ្គោ ភេទប្រុស ជនជាប់ចោទឈ្មោះ [redacted] **ភារក្ស** ភេទប្រុស ជនជាប់ចោទឈ្មោះឈ្មោះ [redacted] **សៀងលី** ភេទប្រុស និងជនជាប់ឈ្មោះ [redacted] **គីមហុង** ភេទប្រុស (ដូចមានអត្ត



Scanned with CamScanner

សញ្ញាណខាងលើ) មកជំនុំជម្រះពីបទ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិបឹងខ្យាង ឃុំបឹងខ្យាង ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល កាលពីថ្ងៃ០៦ ខែកក្កដា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្ដន្ទាទោសតាមមាត្រា ៤០ និងមាត្រា ៤៥ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន តាមដីកាដំណោះស្រាយលេខ ១៣៣២ ដក.ងស ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្ដាល តាមមាត្រា ២៩២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលនាំឱ្យសាលាដំបូងខេត្តកណ្ដាលមានសមត្ថកិច្ចក្នុងការជំនុំជម្រះ៕

**ខ. អំពីដែនកំណត់នៃការប្ដឹងចំពោះអង្គហេតុ និងបុគ្គល**

ដែនកំណត់នៃការប្ដឹងទៅតុលាការចំពោះអង្គហេតុ តាមដីកាដំណោះស្រាយលេខ **១៣៣២ ដក.ងស** ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្ដាល តាមមាត្រា ៣៤៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងដែនកំណត់នៃការប្ដឹងទៅតុលាការចំពោះបុគ្គល តាមមាត្រា ៣៤៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលនាំឱ្យសាលាដំបូងខេត្តកណ្ដាល មានសមត្ថកិច្ចក្នុងការជំនុំជម្រះលើអង្គហេតុដែលប្ដឹងមកតុលាការ និងចំពោះជនជាប់ចោទឈ្មោះ [redacted] **ម៉ាហ្គោ** ភេទប្រុស ជនចោទឈ្មោះ [redacted] **ភារក្ស** ភេទប្រុស ជនជាប់ចោទឈ្មោះ [redacted] **សៀងលី** ភេទប្រុស និងជនជាប់ចោទឈ្មោះ [redacted] **គីមហុង** ភេទប្រុស (ដូចមានក្នុងអត្តសញ្ញាណខាងលើ)៕

**គ. អំពី ពិរុទ្ធភាព**

**១.** តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] **ម៉ាហ្គោ** ឈ្មោះ [redacted] **ភារក្ស** ឈ្មោះ [redacted] **សៀងលី** និងឈ្មោះ [redacted] **គីមហុង** ក្នុងកិច្ចពិភាក្សាដេញដោល បង្ហាញថា ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **ម៉ាហ្គោ** ឈ្មោះ [redacted] **ភារក្ស** ឈ្មោះ [redacted] **សៀងលី** និងឈ្មោះ [redacted] **គីមហុង** មានភាពស៊ីសង្វាក់ទៅនឹងភស្តុតាងជាឯកសារ និងភស្តុតាងជាចម្លើយផ្សេងៗទៀតក្នុងសំណុំរឿងព្រហ្មទណ្ឌនេះ ហើយដែលចម្លើយទាំងអស់នេះ អាចបង្ហាញថា អង្គហេតុដែលប្ដឹងមកតុលាការ ពិតជាកើតមានឡើង ដោយមានពេលវេលា ទីកន្លែង ជនប្រព្រឹត្តអំពើច្បាស់លាស់ ដែលជាមូលដ្ឋានអាចឱ្យតុលាការ បន្តការពិចារណាទៅលើអំពើដែលមាននៅក្នុងអង្គហេតុដែលប្ដឹងមកតុលាការថា តើជាបទល្មើសព្រហ្មទណ្ឌ ឬពុំមែនជាបទល្មើសព្រហ្មទណ្ឌនោះទេ។

**២.** តាមលទ្ធផលកោសលវិច័យគ្រឿងញៀនលេខ **២៧៤៣៩/២០ ម.ព.អ.ជ.គ.ញ** ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២០ របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បង្ហាញថា សារធាតុញៀនដែលបានចាប់យកពីជនជាប់ចោទឈ្មោះ [redacted] **ម៉ាហ្គោ** និងបញ្ជូនទៅកោសលវិច័យ ដែលមានទម្ងន់សរុបស្មើនឹងចំនួន **៤,៥៩ (បួនក្បៀសហាសិបប្រាំបួន)** ក្រាម ជាប្រភេទ មេតំហ្វេតាមីន មានកម្រិតធាតុសុទ្ធចំនួន **៧៦.០១ (ចិតសិបប្រាំមួយក្បៀសសូន្យមួយ) ភាគរយ** នៃទម្ងន់សរុប ស្ថិតក្នុងតារាងទី០២ មាត្រា ០៥ ចំណាត់ថ្នាក់គ្រឿងញៀន ក្នុងតារាងឧបសម្ព័ន្ធច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ហេតុនេះ សារធាតុញៀនប្រភេទ ដែលចាប់យកទម្ងន់សរុបស្មើនឹងចំនួន **៤,៥៩ (បួនក្បៀសហាសិបប្រាំបួន)** ក្រាម មានបរិមាណសុទ្ធ ស្មើនឹងចំនួន **៤,៥៩ (បួនក្បៀសហាសិបប្រាំបួន)** *ក្រាម គុណនឹង* **៧៦.០១ (ចិតសិបប្រាំមួយក្បៀសសូន្យមួយ)** *ចែកនឹង ១០០ (មួយរយ) ស្មើនឹងចំនួន ៣.៤៩ (បីក្បៀសសែសិបប្រាំបួន) ក្រាម* ។



Scanned with CamScanner

៣. តាមសំអាងហេតុចំណុចទី ១ ដល់ចំណុចទី២ នៃចំណុច គ (អំពីពិរុទ្ធភាព) ខាងលើ បានបង្ហាញថា អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] ម៉ាហ្គោ បានបំពេញធាតុសត្យានុម័ត នៃធាតុផ្សំនៃបទល្មើសព្រហ្មទណ្ឌ ដែលអំពើនេះ ត្រូវបានចាត់ទុកជាបទ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** បទល្មើសដែលចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤០ និង មាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដោយហេតុថា នៅថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២០ ជនជាប់ចោទឈ្មោះ [redacted] ម៉ាហ្គោ បានលក់ថ្នាំញៀនឱ្យទៅឈ្មោះ [redacted] **សៀងលី** តែឈ្មោះ [redacted] **គីមហុង** ជាអ្នកមកយកថ្នាំញៀន ប្រាកដមែន និងជនជាប់ចោទឈ្មោះ [redacted] **ភារក្ស** ឈ្មោះ [redacted] **សៀងលី** និងឈ្មោះ [redacted] **គីមហុង** បានបំពេញធាតុសត្យានុម័ត នៃធាតុផ្សំនៃបទល្មើសព្រហ្មទណ្ឌ ដែលអំពើនេះ ត្រូវបានចាត់ទុកជាបទ **ចាត់ចែងឱ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** បទល្មើសដែលចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤២ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដោយហេតុថា អំពើរបស់ជនជាប់ចោទទាំងបី បានដឹកនាំ បែងចែក បញ្ជា ដើម្បីបញ្ចូលសារធាតុញៀនប្រភេទ មេតំហ្វេតាមីន ចូលទៅក្នុងរាយកាយអ្នកដទៃ។

**៤.** តាមសំអាងហេតុចំណុចទី ១ ដល់ចំណុចទី៣ នៃចំណុច គ (ការប្រកាសអំពីពិរុទ្ធភាព) ខាងលើ បានបង្ហាញថា អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] ម៉ាហ្គោ បានបំពេញធាតុអន្តនោម័ត នៃធាតុផ្សំនៃបទល្មើសព្រហ្មទណ្ឌ ដែលអំពើនេះ ត្រូវបានចាត់ទុកជាបទ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** បទល្មើសដែលចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤០ និង មាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដោយហេតុថា នៅថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២០ ជនជាប់ចោទឈ្មោះ [redacted] ម៉ាហ្គោ មានចេតនាក្នុងការលក់ថ្នាំញៀនឱ្យទៅឈ្មោះ [redacted] **សៀងលី** តែឈ្មោះ [redacted] **គីមហុង** ជាអ្នកមកយកថ្នាំញៀន ប្រាកដមែន និងជនជាប់ចោទឈ្មោះ [redacted] **ភារក្ស** ឈ្មោះ [redacted] **សៀងលី** និងឈ្មោះ [redacted] **គីមហុង** បានបំពេញធាតុសត្យានុម័ត នៃធាតុផ្សំនៃបទល្មើសព្រហ្មទណ្ឌ ដែលអំពើនេះ ត្រូវបានចាត់ទុកជាបទ **ចាត់ចែងឱ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** បទល្មើសដែលចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤២ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដោយហេតុថា អំពើរបស់ជនជាប់ចោទ មានចេតនាក្នុងការដឹកនាំ បែងចែក បញ្ជា ដើម្បីបញ្ចូលសារធាតុញៀនប្រភេទ មេតំហ្វេតាមីន ចូលទៅក្នុងរាយកាយអ្នកដទៃ និងដែលជាចេតនាទុច្ចរិតក្នុងការប្រព្រឹត្តបទល្មើស ដោយហេតុថា ជនជាប់ចោទបានដឹង នូវអំពើរបស់ខ្លួនថា ជាបទល្មើស និងអាចព្យាករណ៍បាននូវអំពើរបស់ខ្លួន។

**៥.** តាមសំអាងហេតុចំណុចទី៣ ដល់ចំណុចទី៤ នៃចំណុច គ (អំពីពិរុទ្ធភាព) ខាងលើបានបង្ហាញថា អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] ម៉ាហ្គោ បានបំពេញធាតុផ្សំនៃបទ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** បទល្មើសដែលចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤០ និង មាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងជនជាប់ចោទឈ្មោះ [redacted] **ភារក្ស** ឈ្មោះ [redacted] **សៀងលី** និងឈ្មោះ [redacted] **គីមហុង** បានបំពេញធាតុផ្សំនៃបទ **ចាត់ចែងឱ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** បទល្មើសដែលចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤២ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

**ឃ. អំពីការទទួល ឬមិនទទួលខុសត្រូវព្រហ្មទណ្ឌ**



Scanned with CamScanner

**ឃ.១. មូលហេតុវិបល្លាសស្មារតី**

តាមរយៈភស្តុតាងក្នុងសំណុំរឿង ពុំមានភស្តុតាងណាមួយដែលអាចបញ្ជាក់ថា នៅពេលកំពុងប្រព្រឹត្តបទល្មើស ជនជាប់ចោទឈ្មោះ [redacted] **ម៉ាហ្គោ** ឈ្មោះ [redacted] **ភារក្ស** ឈ្មោះ [redacted] **សៀងលី** និងឈ្មោះ [redacted] **គឹមហុង** កើតមានវិបល្លាសស្មារតី ដែលធ្វើឱ្យបាត់បង់ដឹងខុសត្រូវរបស់ខ្លួន បន្ថយនូវការដឹងខុសត្រូវរបស់ខ្លួន ដោយសារការប្រើប្រាស់គ្រឿងស្រវឹង គ្រឿងញៀន ឬសារធាតុដែលច្បាប់ហាមឃាត់ តាមមាត្រា ៣១ នៃក្រមព្រហ្មទណ្ឌ។ ហេតុនេះ ជនជាប់ចោទ ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌចំពោះអំពើដែលខ្លួនបានប្រព្រឹត្ត តាមមាត្រា ២៤ និងមាត្រា ៣៨ នៃក្រមព្រហ្មទណ្ឌ៕

**ឃ.១. មូលហេតុការអនុញ្ញាតដោយច្បាប់ ឬអាជ្ញាធរ ឬការពារស្របច្បាប់ ឬសច្ឆការណ៍នៃការពារស្របច្បាប់ ឬស្ថានភាពចាំបាច់ ឬ អានុភាពនៃកម្លាំង ឬការបង្ខំ**

តាមរយៈភស្តុតាងក្នុងសំណុំរឿង ពុំមានភស្តុតាងណាមួយដែលអាចបង្ហាញបានថា ជនជាប់ចោទឈ្មោះ [redacted] **ម៉ាហ្គោ** ឈ្មោះ [redacted] **ភារក្ស** ឈ្មោះ [redacted] **សៀងលី** និងឈ្មោ [redacted] **គឹមហុង** បានប្រព្រឹត្តបទល្មើស ក្នុងស្ថានភាពនៃការអនុញ្ញាតដោយច្បាប់ ឬអាជ្ញាធរ តាមមាត្រា ៣២ ការពារស្របច្បាប់ តាមមាត្រា ៣៣ សច្ឆការណ៍នៃការពារស្របច្បាប់ តាមមាត្រា ៣៤ ស្ថានភាពភាពចាំបាច់ តាមមាត្រា ៣៥ អានុភាពនៃកម្លាំង ឬការបង្ខំ មាត្រា ៣៦ នៃក្រមព្រហ្មទណ្ឌនោះទេ។ ហេតុនេះ ជនជាប់ចោទ ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌចំពោះអំពើដែលខ្លួនបានប្រព្រឹត្ត តាមមាត្រា ២៤ និងមាត្រា ៣៨ នៃក្រមព្រហ្មទណ្ឌ៕

**ង. អំពី ការប្រកាសអំពីពិរុទ្ធភាព**

តាមសំអាងហេតុចំណុច គ (អំពី ពិរុទ្ធភាព) និងចំណុច ឃ (អំពីការទទួលខុសត្រូវព្រហ្មទណ្ឌ ខាងលើបង្ហាញថា ជនជាប់ចោទឈ្មោះ [redacted] **ម៉ាហ្គោ** បានបំពេញធាតុផ្សំនៃបទ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** បទល្មើសដែលចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤០ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន, ជនជាប់ចោទឈ្មោះ [redacted] **ភារក្ស** ឈ្មោះ [redacted] **សៀងលី** និងឈ្មោះ [redacted] **គឹមហុង** បានបំពេញធាតុផ្សំនៃបទ **ចាត់ចែងឱ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** បទល្មើសដែលចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤២ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងមានលក្ខខណ្ឌគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌ ហេតុដូច្នេះ តុលាការយល់ឃើញថា ជនជាប់ចោទឈ្មោះ [redacted] **ម៉ាហ្គោ** ភេទប្រុស មានពិរុទ្ធភាពពីបទ **ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** បទល្មើសដែលចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤០ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងជនជាប់ចោទឈ្មោះ [redacted] **ភារក្ស** ឈ្មោះ [redacted] **សៀងលី** និងឈ្មោះ [redacted] **គឹមហុង** មានពិរុទ្ធភាពពីបទ **ចាត់ចែងឱ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** បទល្មើសដែលចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤២ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន

**ច. អំពីការពិចារណាលើស្ថានសម្រាល និងស្ថានទម្ងន់ទោស**

អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] **ម៉ាហ្គោ** ឈ្មោះ [redacted] **ភារក្ស** ឈ្មោះ [redacted] **សៀងលី** និងឈ្មោះ [redacted] **គឹមហុង** មិនបានបង្កើតឱ្យមានស្ថានទម្ងន់ទោសណាមួយចំពោះជនជាប់ចោទ តាមមាត្រា ៨៣ ដល់មាត្រា ៩២ នៃ

ក្រមព្រហ្មទណ្ឌ ហេតុដូច្នេះ តុលាការនឹងសម្រេចពុំពិចារណាអំពីស្ថានទម្ងន់ទោសនោះទេ។ ចំពោះ ស្ថានសម្រាលទោស តាមមាត្រា ៩៤ និងមាត្រា ៩៥ នៃក្រមព្រហ្មទណ្ឌ ពុំមានភស្តុតាង ឬសញ្ញាណណាមួយដែលអាចបង្ហាញបានថា កាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈនៃជនជាប់ចោទតម្រូវ ហេតុដូច្នេះ នឹងសម្រេចពុំពិចារណាអំពីស្ថានសម្រាលទោសនោះទេ៕

**ឍ. អំពីរបបនៃការប្រកាសទោស**

**ឍ.១. ការប្រកាសអំពីមូលទោស**

ផ្អែកតាមកាលៈទេសៈនៃបទល្មើស តាមបុគ្គលិកលក្ខណៈនៃជនជាប់ចោទ តាមសភាពផ្លូវចិត្ត តាមធនធាននិងបន្ទុក តាមមូលហេតុ ព្រមទាំងកិរិយាមារយាទរបស់ជនជាប់ចោទ ក្រោយពេលប្រព្រឹត្តបទល្មើស និងដោយហេតុថា បទល្មើសដែលជនជាប់ចោទបានប្រព្រឹត្តបទ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** គឺជាប្រភេទបទល្មើសដែលចែងឱ្យផ្តន្ទាទោសដាក់ពន្ធនាគារចំនួនពី **០២ (ពីរ) ឆ្នាំ ទៅ ០៥ (ប្រាំ) ឆ្នាំ** និងអាចពិន័យជាប្រាក់ចំនួនពី **៤.០០០.០០០ (បួនលាន) ទៅ ១០.០០០.០០០ (ដប់លាន) រៀល**។ បទ **ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** គឺជាប្រភេទបទល្មើសដែលចែងឱ្យផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ពី **០១ (មួយ) ខែ ទៅ ០៦ (ប្រាំមួយ) ខែ** និងអាចពិន័យជាប្រាក់ចំនួនពី **១០០.០០០ (មួយសែន) រៀល ទៅ ១.០០០.០០០ (មួយលាន) រៀល**។ បទ **ចាត់ចែងឱ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** គឺជាប្រភេទបទល្មើសដែលចែងឱ្យផ្តន្ទាទោសដាក់ពន្ធនាគារចំនួនពី **០២ (ពីរ) ឆ្នាំ ទៅ ០៥ (ប្រាំ) ឆ្នាំ** និងអាចពិន័យជាប្រាក់ចំនួនពី **៤.០០០.០០០ (បួនលាន) ទៅ ១០.០០០.០០០ (ដប់លាន) រៀល**។

តុលាការនឹងសម្រេចប្រកាសមូលទោស ក្នុងទម្រង់ជាការដាក់ទោសដាក់ពន្ធនាគារ ដោយសម្រេចប្រកាសទោសដាក់ពន្ធនាគារលើជនជាប់ចោទឈ្មោះ [redacted] **ម៉ាហ្គោ** ចំនួន **០២ (ពីរ) ឆ្នាំ** ពីបទ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** បទល្មើសដែលចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤០ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងជនជាប់ចោទឈ្មោះ [redacted] **ភារក្ស** ឈ្មោះ [redacted] **សៀងលី** ឈ្មោះ [redacted] **គីមហុង** ចំនួន **០២ (ពីរ) ឆ្នាំ** ពីបទ **ចាត់ចែងឱ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** បទល្មើសដែលចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤២ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ព្រោះថា តាមកាលៈទេសៈនៃបទល្មើស បុគ្គលិកលក្ខណៈនៃជនជាប់ចោទ សភាពផ្លូវចិត្ត ធនធាននិងបន្ទុក មូលហេតុ ព្រមទាំងកិរិយាមារយាទរបស់ជនជាប់ចោទក្រោយពេលប្រព្រឹត្តបទល្មើស ការសម្រេចជ្រើសរើសយកទោសដាក់ពន្ធនាគារ ជាទណ្ឌកម្មព្រហ្មទណ្ឌ នឹងអាចផ្តល់ និងមានប្រយោជន៍នៃទោស ចំពោះជនជាប់ចោទក្នុងការអប់រំកែប្រែ ស្មារតី ផ្លូវចិត្ត អារម្មណ៍ ជាពិសេស គឺការបន្សាបចោលនូវសារធាតុញៀនទាំងស្រុងពីក្នុងរាងកាយ ដើម្បីអាចស្តារនីតិសម្បទាក្នុងការចូលទៅរួមរស់ក្នុងសង្គមគ្រួសារ និងសង្គមជាតិឡើងវិញបាន។

**ឍ.៥. ចំពោះរបបនៃការប្រកាសទោសផ្សេងទៀត**

ចំពោះរបបនៃការប្រកាសទោសផ្សេងទៀត តុលាការនឹងមិនលើកយកមកពិចារណានោះទេ។



Scanned with CamScanner

**ដ. អំពី វត្ថុចាប់យក**

តាមភស្តុតាងក្នុងសំណុំរឿងបង្ហាញថា វត្ថុចាប់យកដែលរួមមាន ម្សៅក្រាមពណ៌សថ្លា ប្រភេទម៉ាទឹកកក ចំនួន ០៧ (ប្រាំពីរ) កញ្ចប់តូច ទូរស័ព្ទដៃ ០១ គ្រឿងម៉ាក NOKIA អ៊ិនចុចពិល ពណ៌ក្រហម និងសម្ភារៈប្រើប្រាស់មួយចំនួន ដែលត្រូវបានចាប់យកពីជនជាប់ចោទឈ្មោះ [redacted] ម៉ាហ្គោ ជនជាប់ចោទឈ្មោះ [redacted] សៀងលី និងជនជាប់ចោទឈ្មោះ [redacted] **គីមហុង** គឺជាឧបករណ៍ សម្ភារៈ ឬវត្ថុណាមួយដែលបានប្រើប្រាស់ក្នុងការប្រព្រឹត្តបទល្មើស ឬដែលសម្រាប់ប្រព្រឹត្តបទល្មើស, វត្ថុ ឬមូលនិធិដែលជាកម្មវត្ថុនៃបទល្មើស, ផលទុន ឬទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស, ឧបភោគភណ្ឌ សម្ភារៈ និងចលនវត្ថុ នៅក្នុងទីកន្លែងដែលបទល្មើសបានប្រព្រឹត្ត។ ហេតុដូច្នេះ តុលាការនឹងសម្រេចរឹបអូសវត្ថុចាប់យកទាំងអស់ដែលបានចាប់យក។

## សេចក្តីសម្រេច

១. ប្រកាសថា មានពិរុទ្ធភាពលើជនជាប់ចោទ៖

ក. ឈ្មោះ [redacted] ម៉ាហ្គោ ភេទប្រុស កើតឆ្នាំ ១៩៩៩ (ដូចមានអត្តសញ្ញាណខាងលើ) ពីបទ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិបឹងខ្យាង ឃុំបឹងខ្យាង ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល កាលពីថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២០ បទល្មើសដែលចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤០ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

ខ. ឈ្មោះ [redacted] **ភារក្ស** ភេទប្រុស កើតឆ្នាំ ២០០១ (ដូចមានអត្តសញ្ញាណខាងលើ) និងឈ្មោះ [redacted] **សៀងលី** ភេទប្រុស កើតឆ្នាំ ១៩៩៥ (ដូចមានអត្តសញ្ញាណខាងលើ) និងឈ្មោះ [redacted] **គីមហុង** ភេទប្រុស កើតឆ្នាំ ២០០០ (ដូចមានអត្តសញ្ញាណខាងលើ) ពីបទ **ចាត់ចែងឱ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** បទល្មើសដែលចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤២ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ហើយត្រូវប្តូរបទចោទប្រកាន់ពីបទ **ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ទៅជាបទ **ចាត់ចែងឱ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិបឹងខ្យាង ឃុំបឹងខ្យាង ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល កាលពីថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២០ បទល្មើសដែលចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤២ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២. ផ្តន្ទាទោសជាទោសដាក់ពន្ធនាគារលើជនជាប់ចោទ៖

ក. ឈ្មោះ [redacted] ម៉ាហ្គោ ភេទប្រុស កើតឆ្នាំ ១៩៩៩ (ដូចមានអត្តសញ្ញាណខាងលើ) ចំនួន **០២ (ពីរ) ឆ្នាំ** ពីបទ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិបឹងខ្យាង ឃុំបឹងខ្យាង ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល កាលពីថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២០ បទល្មើសដែលចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤០ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

ខ. ឈ្មោះ [redacted] **ភារក្ស** ភេទប្រុស កើតឆ្នាំ ២០០១ (ដូចមានអត្តសញ្ញាណខាងលើ) និងឈ្មោះ [redacted] **សៀងលី** ភេទប្រុស កើតឆ្នាំ ១៩៩៥ (ដូចមានអត្តសញ្ញាណខាងលើ) និងឈ្មោះ [redacted] **គីមហុង** ភេទប្រុស កើតឆ្នាំ ២០០០ (ដូចមានអត្តសញ្ញាណខាងលើ) ចំនួន **០២ (ពីរ) ឆ្នាំ** ពីបទ **ចាត់ចែងឱ្យប្រើប្រាស់ដោយខុសច្បាប់នូវ**



Scanned with CamScanner

សារធាតុញៀន ប្រព្រឹត្តនៅភូមិបឹងខ្យាង ឃុំបឹងខ្យាង ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល កាលពីថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២០ បទល្មើសដែលចែងឱ្យផ្ដន្ទាទោសតាមមាត្រា ៤២ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

៣. វត្ថុចាប់យកដែលរួមមានម្សៅក្រាមពណ៌សថ្លា ប្រភេទម៉ាទឹកកក ចំនួន ០៧ (ប្រាំពីរ) កញ្ចប់តូច, ទូរស័ព្ទដៃ ០១ គ្រឿងម៉ាក NOKIA អ៊ិនចុចពិល ពណ៌ក្រហម និងសម្ភារៈប្រើប្រាស់មួយចំនួន ត្រូវរឹបអូស។

*សំណុំរឿងព្រហ្មទណ្ឌនេះ ត្រូវបានជំនុំជម្រះជាសាធារណៈនៅចំពោះមុខជនជាប់ចោទ។*

*សាលក្រមព្រហ្មទណ្ឌនេះ ប្រកាសជាសាធារណៈ នៅថ្ងៃ សុក្រ ០៦ រោច ខែកត្ដិក ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤ ត្រូវនឹងថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០២០ វេលាម៉ោង ០២ និង ០០ នាទី នៅសាលសវនាការលេខ ៥។*

*ភាគីដែលមានបំណងធ្វើបណ្ដឹងឧទ្ធរណ៍ ឬបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងសាលក្រមនេះ ត្រូវធ្វើបណ្ដឹងឧទ្ធរណ៍ និងបណ្ដឹងឧទ្ធរណ៍នេះ តាមការកំណត់របស់ច្បាប់។*

ក្រឡាបញ្ជីសវនាការ

ហត្ថលេខា និងត្រា [redacted]

ចៅក្រមជំនុំជម្រះ

ហត្ថលេខា និងត្រា [redacted]

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃ សុក្រ ០៦ រោច ខែកត្ដិក ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

ខេត្តកណ្ដាល ថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០២០

ក្រឡាបញ្ជីសវនាការ

[redacted]

បានឃើញ

ចៅក្រមជំនុំជម្រះ

[redacted]



Scanned with CamScanner